មជ្ឈមណ្ឌលឯកសារកម្ពុជា

## គម្រោងស្តីអំពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ការបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

**រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា**

**វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានលើកទី១០ មណ្ឌលខេត្តកំពង់ចាម**

**៧-១២ កញ្ញា ២០១៣**

មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា មានកិត្តិយសសូមប្រកាសនូវកម្មវិធីស្តីអំពីការបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» សម្រាប់គ្រូប្រវត្តិវិទ្យា ភូមិវិទ្យា ភាសាខ្មែរ និងសីលធម៌ពលរដ្ឋ នៅទូទាំងប្រទេស ។ កម្មវិធីថ្មីនេះមិនត្រឹមតែជាជំហានឆ្ពោះទៅមុខដ៏មានសារៈសំខាន់មួយ នៅក្នុងការកសាងវប្បធម៌នៃការផ្សះផ្សា និងសន្តិភាពតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគាំទ្រដល់គោលការណ៍សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋទៀតផង ។

បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងខែមករា ឆ្នាំ១៩៧៩ ការខិតខំប្រឹងប្រែងនៅក្នុងការបង្រៀនប្រជាជនកម្ពុជា និងយុវជនជំនាន់ក្រោយ មានកម្រិតនៅត្រឹមការឃោសនានយោបាយ ឬរឿងរ៉ាវដែលត្រូវបានចែករំលែកជាគ្រួសារ រវាងឪពុកម្តាយនិងកូនចៅ ។ ការបង្រៀនបែបនេះត្រូវបានផ្លាស់ប្តូរនៅក្នុងឆ្នាំ១៩៩១ ជាមួយនឹងការចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ។ ការចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងនេះ សម្គាល់នូវដំណើរអន្តរកាលឆ្ពោះទៅកាន់កម្មវិធីសិក្សាថ្មីមួយ ដែលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដកចេញពីកម្មវិធីសិក្សា ។ ១០ឆ្នាំក្រោយមកទៀត ប្រជាជនកម្ពុជាត្រូវបានលើកទឹកចិត្តឲ្យផ្តោតទៅលើសន្តិភាព និងការផ្សះផ្សាជាតិ ដែលប្រការនេះធ្វើឲ្យមានការខាតបង់ដល់ការយល់ដឹង និងការចង់ដឹងចង់ឮផ្នែកប្រវត្តិសាស្ត្រ ។ សម្រាប់ប្រជាជនជាច្រើន វាមានសុវត្ថិភាពជាងនៅក្នុងការកប់ចោលនូវអតីតកាល ជាជាងប្រឈមមុខនឹងអតីតកាល ។ អស់រយៈពេលជាច្រើនឆ្នាំកន្លងផុតទៅ និងដោយមានការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) ការភ័យខ្លាចដែលបន្សល់មានពីមុនមក ចំពោះការកើតមានឡើងវិញនូវសង្គ្រាម បានសាបរលាបទៅវិញ ។ រយៈពេល២៨ឆ្នាំក្រោយពីការដួលរលំនៃរបបខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជា បានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដែលត្រូវបានក្រសួងអប់រំ យុវជន និងកីឡា អនុម័តទទួលយកថាជាឯកសារយោងចម្បងមួយ សម្រាប់គ្រូនិងសិស្សថ្នាក់មធ្យមសិក្សាទូទាំងប្រទេស

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

នៅក្នុងឆ្នាំ២០០៧។ សៀវភៅណែនាំសម្រាប់គ្រូបង្រៀន ក៏ត្រូវបានបោះពុម្ពជាមួយគ្នាដែរនៅក្នុងឆ្នាំ២០០៩ ដើម្បីផ្តល់ឲ្យគ្រូនូវវិធីសាស្ត្របង្រៀនបែបសម័យទំនើប។ ដោយមានការគាំទ្រពីឯកសារបង្រៀនទាំងនេះ នៅក្នុងខែឧសភា ឆ្នាំ២០១១ ក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលសៀវភៅសិក្សាសង្គមរបស់ខ្លួនសម្រាប់ថ្នាក់ទី៩និងថ្នាក់ទី១២ ដោយបានបញ្ចូលផ្នែកខ្លះនៃសៀវភៅប្រវត្តិសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទៅក្នុងមុខវិជ្ជាប្រវត្តិវិទ្យា ភាសាខ្មែរ និងសីលធម៌ពលរដ្ឋ។

ដោយមើលឃើញពីការវិវឌ្ឍដ៏គួរឲ្យកត់សម្គាល់បែបនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវគ្គបណ្តុះបណ្តាលជាច្រើន។ ចាប់តាំងពីឆ្នាំ២០០៩មក គ្រូជាង៣០០០នាក់ ដែលបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ភាសាខ្មែរ និងសីលធម៌ពលរដ្ឋ ទទួលបានការបណ្តុះបណ្តាល។ ដើម្បីជាប្រយោជន៍ដល់ការពង្រីកបន្ថែមនូវលទ្ធផលនៃកម្មវិធីនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានអភិវឌ្ឍកម្មវិធីសិក្សា សម្រាប់ផ្នែកផ្សេងទៀតនៃសង្គមស៊ីវិលនិងរដ្ឋាភិបាល។ សាស្ត្រាចារ្យសាកលវិទ្យាល័យ ដែលបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មន្ត្រីប៉ូលិស មន្ត្រីទាហាន និងគរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ ទទួលបានការបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការបណ្តុះបណ្តាលទៅលើមុខវិជ្ជាជំនាញជាក់លាក់ផ្សេងៗទៀត ដែលទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍។ បន្ថែមពីលើការរីកចំរើនទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា នឹងចាប់ផ្តើមកម្មវិធីមួយបន្ថែមទៀត ដែលនឹងបណ្តុះបណ្តាលគរុសិស្ស នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ នៅក្នុងខេត្តតាកែវ កំពង់ចាម ព្រៃវែង កណ្តាល បាត់ដំបង និងរាជធានីភ្នំពេញ។

វគ្គបណ្តុះបណ្តាលគ្រូបង្រៀន គឺជាវេទិកាដ៏មានឥទ្ធិពលមួយ សម្រាប់បង្កើតឲ្យមានវប្បធម៌មួយដែលឲ្យតម្លៃសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ការយោគយល់គ្នាផ្នែកប្រវត្តិសាស្ត្រ ការត្រិះរិះពិចារណា និងការពិនិត្យមើលសកម្មភាពរបស់ខ្លួនប្រកបដោយការពិចារណា គឺជាទស្សនាទាន និងដំណើរការជាចម្បង នៅក្នុងរាល់កម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍។ ការបណ្តុះបណ្តាលគឺជាមធ្យោបាយដ៏មានសារៈសំខាន់មួយនៅក្នុងការបណ្តុះជំនាញទាំងនេះ ក៏ដូចជានៅក្នុងការផ្តល់នូវមេរៀនទាំងឡាយ ដែលគ្រូអាចយកទៅប្រើប្រាស់នៅតាមថ្នាក់រៀនបាន។ សេចក្តីណែនាំគោលនៅក្នុងវគ្គបណ្តុះបណ្តាល គឺធ្វើយ៉ាងណាឲ្យគ្រូរៀនតាមរយៈការធ្វើសកម្មភាព។ គ្រូអនុវត្តមេរៀនដែលរួមមានការណែនាំអំពីការពិភាក្សា ការងារជាក្រុមប្រកបដោយអន្តរសកម្មភាព និងវិធីសាស្ត្រអាន ដែលនាំទៅដល់ការយល់ដឹងកម្រិតខ្ពស់ មិនត្រឹមតែដើម្បីពង្រីកការយល់ដឹងរបស់ខ្លួន អំពីប្រវត្តិសាស្ត្រកម្ពុជា

ប្រជាធិបតេយ្យតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីបង្កើនការអនុវត្តវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌលទៀតផង ។ នៅក្នុងន័យនេះ គ្រូត្រូវបានជម្រុញឲ្យក្លាយទៅជាអ្នករៀនសូត្រដ៏សកម្ម ដើម្បីប្រែក្លាយវិធីសាស្ត្របង្រៀនបែបសម័យទំនើប ឲ្យអាចយកទៅប្រើប្រាស់នៅក្នុងថ្នាក់រៀនរបស់កម្ពុជាបាន ។

នាពេលបច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នតែមួយគត់ ដែលក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការអនុញ្ញាតឲ្យធ្វើការជាមួយគ្រូនៅទូទាំងប្រទេស ទៅលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ជាងនេះទៅទៀត សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាប្រភពធនធានតែមួយគត់ ដែលត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់នៅទូទាំងប្រទេស ដោយក្រសួងអប់រំ យុវជន និងកីឡា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ដើម្បីទទួលបាននូវការអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជានិរន្តរ៍ នៅក្នុងប្រទេសកម្ពុជា និងដើម្បីចូលរួមចំណែកដល់ការកសាងសន្តិភាព ការផ្សះផ្សាជាតិ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ការបណ្តុះបណ្តាលបន្ថែមទៀត ត្រូវតែធ្វើឡើង ដើម្បីបណ្តុះបណ្តាលគ្រូដែលបង្រៀនមុខវិជ្ជាទាំងបីខាងលើ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា នឹងបើកវគ្គបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ដល់គ្រូមូលដ្ឋានចំនួន១០០នាក់ ដែល៥០នាក់មកពីខេត្តកំពង់ចាម និង៥០នាក់ទៀតមកពីខេត្តក្រចេះ នៅថ្ងៃទី៧-១២ កញ្ញា ២០១៣ ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលោក ម៉ម សុវណ្ណ truthsovann@dccam.org
www.dccam.org I www.cambodiatribunal.org I www.cambodiasri.org

វគ្គបណ្តុះបណ្តាលទទួលបានជំនួយទ្រទ្រង់ពី វិទ្យាស្ថានសន្តិភាពសហរដ្ឋអាមេរិក (USIP) ។ ប្រតិបត្តិការគោលទទួលបានជំនួយទ្រទ្រង់ពីទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) (២០១៣-២០១៤)